## សន្និសីទលើកទី១១ នៃ សមាគមអាស៊ីនៃការសិក្សាប្រៀបធៀបពីការអប់រំ (CESA)

## សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី៨ ឧសភា ២០១៨

**ខេត្តសៀមរាប៖** វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ-CDRI) ក្នុងភាពជាដៃគូជាមួយសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា (PUC) បានទទួលរៀបចំសន្និសីទលើកទី១១ នៃសមាគមអាស៊ីនៃការសិក្សាប្រៀបធៀបពីការអប់រំ (CESA) នៅថ្ងៃទី ១១-១២ ឧសភា ២០១៨ នៅសណ្ឋាគារសុខាល័យអង្គរ ក្នុងខេត្តសៀមរាបដែលមានឧទ្យានប្រាសាទបុរាណអង្គរ ជាតំបន់បេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ។ ប្រធានបទសម្រាប់សន្និសីទឆ្នាំ២០១៨ នេះ គឺ **"ការអប់រំ និងវឌ្ឍនភាពសង្គម: ការយល់ដឹងផ្អែកលើទស្សនវិស័យប្រៀបធៀប"**។

CESA ជាសមាគមបញ្ញាវន្តផ្នែកអប់រំនៅអាស៊ី និងតំបន់ផ្សេងៗទៀត ដែលបានចូលរួមក្នុងការសិក្សាប្រៀបធៀបនូវប្រព័ន្ធអប់រំ ប្រពៃណី និងរបៀបអនុវត្តការអប់រំ។ CESA បានកកើតឡើងក្នុងឆ្នាំ១៩៩១ ក្នុងគោលដៅលើកកម្ពស់ការសិក្សាប្រៀបធៀបពីការអប់រំ ឲ្យក្លាយជាមុខវិជ្ជាសិក្សាមួយក្នុងទូទាំងអាស៊ី និងផ្តល់សម្លេងកាន់តែច្រើនដល់ទ្វីបអាស៊ី ក្នុងការជជែកវែកញែកថ្នាក់សកលស្តីពីការអប់រំ។ សន្និសីទ CESA ក្នុងពេលកន្លងមក បានធ្វើឡើងនៅប្រទេស ចិន ឥណ្ឌូនេស៊ី ហុងកុង ជប៉ុន ម៉ាឡេស៊ី ហ្វីលីពីន កូរ៉េខាងត្បូង តៃវ៉ាន់ និង ថៃ។

នាបច្ចុប្បន្ន វិស័យអប់រំកំពុងទទួលបានអាទិភាពខ្ពស់ ហើយការពង្រឹងគុណភាពការបង្រៀន និងការរៀនសូត្រនៅគ្រប់កម្រិតនៃការអប់រំ គឺជា ចំណុចស្នូលនៅក្នុងរបៀបវារៈកំណែទម្រង់វិស័យអប់រំរបស់រាជរដ្ឋាភិបាល ដូចមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ សន្និសីទនេះដើរតួនាទីជាវេទិកាថ្នាក់តំបន់មួយ សម្រាប់ឲ្យបញ្ញាវន្ត អ្នកសិក្សាស្រាវជ្រាវ អ្នកអនុវត្តន៍ និងអ្នកកសាងគោលនយោបាយ ខាងផ្នែកសិក្សាប្រៀបធៀបពីការអប់រំក្នុងពិភពលោក ធ្វើការពិភាក្សាលើបញ្ហាសំខាន់ៗស្តីពីវឌ្ឍនភាពសង្គមដែលអាចសម្រេចបានតាមរយៈការអប់រំ និងដើម្បីឆ្លុះបញ្ចាំងឲ្យឃើញថា តើយើងសំដៅទៅ ឬផ្តោតទៅលើអ្វី នៅពេលយើងលើកឡើងថា ការអប់រំគឺជាឧបករណ៍មួយសម្រាប់វឌ្ឍនភាពសង្គម។

សន្និសីទនេះមានគោលដៅជំរុញឲ្យបញ្ញាវន្តចូលរួមយ៉ាងផុសផុលក្នុងការពិភាក្សាពីប្រធានបទ ដូចជា តើយើងមានចក្ខុវិស័យជាក់លាក់យ៉ាងណា ស្តីពីសង្គមល្អប្រសើរដែលយើងចង់ឈានទៅដល់? តើការអប់រំអាចចូលរួមយ៉ាងណាក្នុងវឌ្ឍនភាពនេះ? តើយើងគួរផ្តល់សារៈសំខាន់ប៉ុណ្ណាដល់ការអប់រំ ដោយស្វែងយល់ថា វាមិនគ្រាន់តែជាឧបករណ៍ដើម្បីសម្រេចបាន ប៉ុន្តែជាធាតុផ្សំមួយនៃ ជីវិតល្អប្រសើរដែលយើងចង់បាន?

សន្និសីទនេះមានអ្នកចូលរួមប្រមាណ ៣៥០នាក់ មកពីជាង ១៥០គ្រឹះស្ថានសិក្សានៅទូទាំងទ្វីបអាស៊ី និងតំបន់ផ្សេងៗទៀត និងមានការចូលរួមចែករំលែកតាមរយៈការធ្វើបទបង្ហាញរហូតដល់ជាង ២៥០ប្រធានបទ។ អ្នកធ្វើបទបង្ហាញតាមវគ្គនានាមានមកពី ប្រទេស អូស្ត្រាលី កម្ពុជា កាណាដា ចិន ឥណ្ឌា ជប៉ុន កូរ៉េខាងត្បូង អង់គ្លេស និង សហរដ្ឋអាមេរិក។

សន្និសីទនេះ ទទួលស្វាគមន៍អ្នកតំណាងប្រព័ន្ធផ្សព្វផ្សាយនានាដែលមកចូលរួមយកព័ត៌មាន និងរាយការណ៍ពីដំណើរការសន្និសីទ។ ព័ត៌មានលំអិតផ្សេងៗទៀត មានចុះក្នុងកម្មវិធីជូនភ្ជាប់។ សម្រាប់សំណួរផ្សេងៗស្តីពីការរៀបចំសន្និសីទ សូមទាក់ទង លោកស្រី ស៊ន សីដា ទូរស័ព្ទលេខ (៨៥៥) ១៧ ៨៩៩ ៨៧៧ ឬ seyda@cdri.org.kh។ សម្រាប់ទីកន្លែងសន្និសីទ សូមទាក់ទងតាមរយៈ ទូស័ព្ទលេខ (៨៥៥) ៦៣ ៩៦៨ ២២២ ឬ info@sokhalayangkor.com ឬ www.sokhalayangkor.com។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

CESA 2018: https://cdri.org.kh/cesa/ CDRI: www.cdri.org.kh PUC: www.puc.edu.kh